**ប្រការ ៣៩ :** នឹងត្រូវប្រកាសថាត្រូវបានប្រលងលើកទី២ បេក្ខជនទាំងឡាយណា ដែលមិនបានប្រកាស ថាប្រលងជាប់លើកទី១ហើយបាន ពិន្ទុសរុបចាប់ពី ១៥០ ឡើងទៅដោយមិនគិតពិន្ទុសូន្យ ចំពោះមុខវិជ្ជាណាមួយ ។

**ប្រការ ៤០ :** បទប្បញ្ញត្តិស្តីពីការរៀបចំប្រលងសញ្ញាប័ត្រមធ្យមសិក្សាភូមិភាគ២ ពីមុន ៗ ទាំងឡាយណាដែល ផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤១ :** ប្រធានមន្ទីរ និង ប្រធាននាយកដ្ឋានចំណុះទូទៅ និង មត្តេយ្យសិក្សា និង អង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តតាមភារកិច្ច រៀង ៗ ខ្លួន ដើម្បីអោយបានសំរេចនូវប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

## ៦ - និស្តីការរដ្ឋមន្ត្រី ក្រសួងសុខាភិបាល

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ០៦៨ ស.ឧបខ្ញ**

**ស្តីពីការកំណត់តួនាទី ភារកិច្ច របស់ភ្នាក់ងារ**

**ត្រួតពិនិត្យឱសថនៅតាមច្រកព្រំដែន**

* * *

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ០៥ តុលា ១៩៩៥ ស្តីពីការរំសាយនិងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែននិងផ្លូវគមនាគមន៍នៅ ទូទាំងព្រះរាជាណាចក្រកម្ពុជា
- យោងតាមសភាពការណ៍ចាំបាច់ និងដើម្បីទទួលអនុវត្ត

**សម្រេច**

**ប្រការ ១ :** ភ្នាក់ងារត្រួតពិនិត្យឱសថនៅតាមព្រំដែនមានមុខងារសំខាន់ក្នុងការត្រួតពិនិត្យការអនុវត្តន៍ បណ្តាបទដ្ឋាន ក្បួនច្បាប់ដែលពាក់ព័ន្ធនឹងសកម្មភាពនាំចូល នាំចេញផលិតផលឱសថសំដៅ ធានាគុណភាពឱសថនាំចូលនិងរាំងស្កាត់ការហូរចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា នូវផលិតផលឱសថដែលគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ ២ :** មុខទំនិញដែលមានក្នុងកម្មវត្ថុនៃការត្រួតពិនិត្យរបស់ក្រសួងសុខាភិបាលរួមមាន ៖

- ឱសថសម័យនិងបូរាណគ្រប់ប្រភេទ
- វត្ថុធាតុដើម សំរាប់ផលិតកម្មឱសថ
- សំភារៈបរិក្ខារពេទ្យ និង សំភារៈបរិក្ខារ ប្រតិករមន្ទីរពិសោធន៍វេជ្ជសាស្ត្រឱសថសាស្ត្រ
- ឈាម និង ផលិតផល ដែលបានមកពីឈាម
- សេរ៉ូម វ៉ាក់សាំង
- គ្រឿងញៀនតារាង I - II -III និង IV ដែលមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន
- គ្រឿងសំអាង និងផលិតផលអានាម័យ ដែលផ្សំឡើងដោយមានជាតិសកម្ម ឱសថ។

**ប្រការ ៣ :** ក្រុមភ្នាក់ងារត្រួតពិនិត្យឱសថ ជាផ្នែកមួយស្ថិតនៅក្រោមឱវាទរបស់ក្រសួងសុខាភិបាលមានទី ចាត់ការកណ្តាលនៅក្នុងនាយកដ្ឋានឱសថនិងផ្គត់ផ្គង់ ។